Victorian Fisheries AUTHORITY



# ចូរមានសុវត្ថិភាពនៅពេលស្ទូចត្រីពីលើផ្ទាំងថ្ម

## ស្ទូចត្រីពីលើផ្ទាំងថ្មដោយសុវត្ថិភាព

ពាក់អាវការពារជីវិតឱ្យបានគ្រប់ពេល នៅពេលស្ទូចត្រី ពីលើផ្ទាំងថ្ម

ការស្ទូចត្រីពីលើផ្ទាំងថ្ម គឺជាវិធីដ៏ល្អមួយដើម្បីចាប់ត្រី និងរីករាយនៅខាងក្រៅអគារ ប៉ុន្តែវាក៏អាចមានគ្រោះថ្នាក់ផងដែរ។

ចាប់តាំងពីខែកក្កដា ឆ្នាំ 2000 និងខែមករា ឆ្នាំ 2022 មានមនុស្សចំនួន 21 នាក់បានលង់ទឹកស្លាប់នៅក្នុងរដ្ឋវិចថូរៀ ខណៈពេលដែលកំពុងស្ទូចត្រីពីលើផ្ទាំងថ្ម។ គ្មានអ្នកណាម្នាក់បានពាក់អាវការពារជីវិតទេ។

ការពាក់អាវការពារជីវិតនៅពេលស្ទូចត្រីពីលើផ្ទាំងថ្ម ជួយសង្គ្រោះជីវិត។

## ច្បាប់ថ្មីនឹងចូលជាធរមាន

ចាប់ពីថ្ងៃទី 1 ខែមីនា ឆ្នាំ 2022 អ្នកស្ទូចត្រីពីលើផ្ទាំងថ្ម ត្រូវតែពាក់អាវការពារជីវិត នៅតាមទីតាំងដែលមានហានិភ័យខ្ពស់ចំនួន 10 នៅទូទាំងរដ្ឋវិចថូរៀ។

ច្បាប់នេះនឹងត្រូវបានសាកល្បងរយៈពេលពីរឆ្នាំ។

## តើទីតាំងដែលមានហានិភ័យខ្ពស់ទាំង 10 នោះ ស្ថិតនៅកន្លែងណាខ្លះ?

ជនណាដែលស្ទូចត្រីនៅតាមទីតាំងទាំងនេះ ត្រូវតែពាក់អាវការពារជីវិត ចាប់ពីថ្ងៃទី 1 ខែមីនា ឆ្នាំ 2022៖

1. ផ្ទាំងថ្មនៅជិតកន្លែងចតរថយន្តមានទឹកផ្លុំបក់បោក (blowholes carpark) នៅក្បែរ Cape Bridgewater
2. Artillery Rocks ភាគខាងលិចនៃតំបន់ជនបទ Lorne
3. ផ្ទាំងថ្មនៅទល់មុខ Sheoak Falls ភាគខាងត្បូងនៃទីជនបទ Lorne
4. ផ្ទាំងថ្ម Sorrento Back Beach
5. ឆ្នេរសមុទ្រលេខ 16 នៅក្រោយឆ្នេរសមុទ្រទីជនបទ Rye
6. ផ្ទាំងថ្មប៉មបញ្ចាំងភ្លើងនាំផ្លូវនាវានៅ Cape Schanck
7. ថ្ម Bushrangers Bay ភាគខាងកើតនៃ Cape Schanck
8. Pyramid Rocks, Phillip Island
9. ផ្ទាំងថ្មនៅចុងខាងត្បូងនៃផ្លូវ Potters Hill Road, San Remo
10. Punchbowl Rocks នៅជិត San Remo

ផែនទីលម្អិតបន្ថែមទៀតនៃទីតាំងនីមួយៗ មាននៅលើគេហទំព័ររបស់អាជ្ញាធរជលផល រដ្ឋវិចថូរៀ (Victorian Fisheries Authority - VFA) នៅត្រង់៖ vfa.vic.gov.au/rockfishing ឬស្កេនកូដ QR នៅលើទំព័រម្ខាងទៀត។



Victorian Fisheries AUTHORITY

## តើខ្ញុំត្រូវការអាវការពារជីវិតប្រភេទណា?

អាវការពារជីវិតរបស់អ្នក ត្រូវតែអនុលោមតាមស្តង់ដារអូស្ត្រាលី (Australian Standard - AS 4758) ហើយត្រូវតែជា៖

- អាវការពារជីវិតកម្រិត 50S ឬខ្ពស់ជាងនេះ (ឧទាហរណ៍ ប្រភេទ 3 ឬខ្ពស់ជាងនេះ)
- ទំហំត្រឹមត្រូវរបស់អ្នក
- ដំណើរការល្អ (ឧទាហរណ៍ ក្លាស់គន្លឹះដំណើរការល្អ និងខ្សែសំប៉ែតមិនដាច់រហែក)
- ពាក់បានត្រឹមត្រូវ (ខ្សែរូត ក្លាស់គន្លឹះ និងបង់ស្អិតទាំងអស់ត្រូវតែបានចងរឹតជាប់ល្អ
- ថែទាំជាទៀងទាត់ ប្រសិនបើអាចបំប៉ោងបាន។

មិនត្រូវប្រើប្រាស់អាវការពារជីវិត ដែលពឹងផ្អែកទាំងស្រុងលើការផ្លុំបំប៉ោងដោយមាត់ឡើយ។

## អាវការពារជីវិតដែលសមរម្យសម្រាប់មនុស្សពេញវ័យ

| | |
|---|---|
| កម្រិត 100<br>(ប្រភេទ 1) |  |
| កម្រិត 50<br>(ប្រភេទ 2) |  |
| កម្រិត 50S<br>(ប្រភេទ 3) |  |

## តើកុមារត្រូវការអាវការពារជីវិតទេ?

ប្រាកដណាស់ ក្មេងណាម្នាក់ដែលស្ថិតក្រោមការគ្រប់គ្រងរបស់អ្នក ត្រូវតែពាក់អាវការពារជីវិត ទោះបីជាពួកគេមិនស្ទូចត្រីក៏ដោយ។ អាវការពារជីវិតរបស់កុមារត្រូវតែ៖

- អនុលោមតាម Australian Standard (AS 4758) និង
- ត្រូវតែជាអាវការពារជីវិតកម្រិត 100 ឬខ្ពស់ជាងនេះ (ឧទាហរណ៍ អាវការពារជីវិត ប្រភេទ 1 ឬខ្ពស់ជាងនេះ)

## អាវការពារជីវិតដែលសមរម្យសម្រាប់កុមារ

កម្រិត 100 (ប្រភេទ 1 ឬខ្ពស់ជាងនេះ)





## ចុះបើខ្ញុំមិនស្ទូចត្រីពីលើផ្ទាំងថ្មទេ?

ប្រសិនបើអ្នកលើនៅផ្ទាំងថ្ម ក៏ប៉ុន្តែមិនស្ទូចត្រីទេ VFA សូមលើកទឹកចិត្តអ្នកឱ្យពាក់អាវការពារជីវិត ក៏ប៉ុន្តែអ្នកមិនបានតម្រូវដោយច្បាប់ឱ្យពាក់ឡើយ។

## ព័ត៌មានបន្ថែម

សម្រាប់ព័ត៌មានបន្ថែមអំពីការរក្សាសុវត្ថិភាពនៅពេលស្ទូចត្រីពីលើផ្ទាំងថ្ម រួមទាំងកូនសៀវភៅជាច្រើនភាសា សូមចូលមើលគេហទំព័រ VFA នៅត្រង់៖ vfa.vic.gov.au/rockfishing ឬស្កេនកូដ QR ខាងក្រោម។

We're hooked on SAFETY

VICTORIA State Government